ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា


ប្រធានគណៈមេធាវី

មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី សាំង វណ្ណះ
២-មេធាវី អ៊ុង គិរិយា
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ីវ ប៊ុលី
៥-មេធាវី ខៀវ សំបូរ
៦-មេធាវី ជា សុកនួន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ថាន ផានិត
៩-មេធាវី ជូ ចាន់ធីរ៉ា
១០-មេធាវី កេង សុម៉ាឡា
១១-មេធាវី ម៉ី ឧសភា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីវ សុវណ្ណា
១៤-មេធាវី ឈីវ តិរម្យ
១៥-មេធាវី សំ សុគង់
១៦-មេធាវី នង មាននួ
១៧-មេធាវី អ៊ូ ធីតាពៅ
១៨-មេធាវី លី ពីង
១៩-មេធាវី យឹម វិស្សុត
២០-មេធាវី លឹម ច័ន្ទលីដា
២១-មេធាវី កែ វិសាល
២២-មេធាវី ហូ លីហួវ
២៣-មេធាវី វ៉ា ពិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន វិមានចំប៉ា
២៧-មេធាវី ឈី សម្បត្តិ


លេខ: ០៤០ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៦

# សេចក្តីសម្រេច

## ស្តីពី

## ការអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈជាមេធាវីកម្មសិក្សា

## ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- បានឃើញសេចក្តីសម្រេចលេខ ០១៣/សសគម/១៦ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ របស់គណៈមេធាវី ស្តីពីការអនុញ្ញាតឱ្យលោក **កុក យូឡេង** ចូលប្រកបវិជ្ជាជីវៈមេធាវី
- បានឃើញកំណត់ហេតុសច្ចាប្រណិធានលេខ ០៥ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍
- យោងតាមសំណើរបស់សាមីខ្លួន
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦


អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៖១៩៨៧ , ទូរស័ព្ទ: (៨៥៥-២៣) ៨៦៤ ០៧៨
ទូរសារ: (៨៥៥-២៣) ៨៦៤ ០៧៦, E-mail: info@bakc.org.kh, website: www.bakc.org.kh

# ស ម្រេ ច

**ប្រការ ១.-** លោកមេធាវី **ភុក យូឡេង** អត្តលេខ **១១៧១ T** ត្រូវបានអនុញ្ញាតឱ្យធ្វើកម្មសិក្សារយៈពេល ១២(ដប់ពីរ)ខែ ជាមួយលោកមេធាវី **លឹម វណ្ណា** នៅ **ក្រុមមេធាវី វណ្ណា និង សហការី** ដែលមានអាសយដ្ឋានស្ថិតនៅ**ផ្ទះលេខ B៧៧$E_0$ ផ្លូវបេតុងទី ២ ភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ** ចាប់ពីថ្ងៃចេញសេចក្ដីសម្រេចនេះតទៅ។

**ប្រការ ២.-**
- រាល់ទំនាក់ទំនង និងគ្រប់លិខិតរបស់កម្មសិក្សាការី ដែលធ្វើឡើងក្នុងក្របខ័ណ្ឌប្រកបវិជ្ជាជីវៈរបស់ខ្លួន ត្រូវមានហត្ថលេខាយល់ព្រមពីគ្រូកម្មសិក្សា។
- គ្រប់ការងារកម្មសិក្សារបស់កម្មសិក្សាការី ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវផ្ទាល់របស់គ្រូកម្មសិក្សា។
- ចប់រយៈពេលកម្មសិក្សា កម្មសិក្សាការី ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវឯកសារសំអាងទាំងអស់ សម្រាប់ដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេច។

**ប្រការ ៣.-** កម្មសិក្សាការីត្រូវចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលនានារបស់គណៈមេធាវី និងចូលរួមគ្រប់សកម្មភាពដែលចាត់តាំងដោយគណៈមេធាវី។

**ប្រការ ៤.-** កម្មសិក្សាការីត្រូវមានកាតព្វកិច្ចជួយការពារក្ដីជូនជនក្រីក្រតាមការចាត់តាំងរបស់គណៈមេធាវី។

**ប្រការ ៥.-** អគ្គលេខាធិការ អគ្គហេរញ្ញិក គ្រូកម្មសិក្សា និងសាមីខ្លួន ត្រូវអនុវត្តសេចក្ដីសម្រេចនេះតាមមុខការរៀងៗខ្លួន៕

**ចម្លងជូន:**

-ក្រុមប្រឹក្សាគណៈមេធាវី

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៥

-ឯកសារ-កាលប្បវត្តិ

ORDRE DES AVOCATS DU ROYAUME DU CAMBODGE

**មេធាវី.ប៊ុន_ហុន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា | |
|---|---|
| ចូល | -លេខ: ៤១៧ |
| | -ម៉ោង: ១០.៣០ |
| | -ថ្ងៃ ខែ ឆ្នាំ: ២៩.២.១៦ |
| | -បញ្ជូន: |

# ពាក្យសុំធ្វើកម្មសិក្សា

ខ្ញុំបាទឈ្មោះ **កុក យុឡេង** ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា មានអាសយដ្ឋានផ្ទះលេខ ១៤ ផ្លូវជាតិលេខ ០៣ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

## សូមគោរពជូន
## លោកប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ:** សំណើរសុំធ្វើកម្មសិក្សារយៈពេល ១២ខែ ជាមួយលោកមេធាវី **លឹម វណ្ណា** ។

**យោង:** - មាត្រា ៣៥, ៣៦ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

- ការធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍ នាថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន លោកប្រធាន មេត្តាជ្រាបថា: បន្ទាប់ពីក្រុមប្រឹក្សាគណៈមេធាវីបានសម្រេចអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវី ខ្ញុំបាទបានធ្វើសច្ចាប្រណិធាននៅចំពោះមុខសាលាឧទ្ធរណ៍រួចហើយកាលពីថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ហើយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី តម្រូវឲ្យខ្ញុំបាទធ្វើកម្មសិក្សារយៈពេល ១២ខែ មុននឹងក្លាយជាមេធាវីពេញសិទ្ធិ ។ ដូច្នេះខ្ញុំបាទស្នើសុំធ្វើកម្មសិក្សា ជាមួយលោកមេធាវី **លឹម វណ្ណា** ដែលមានការិយាល័យឈ្មោះ **ក្រុមមេធាវី វណ្ណា និងសហការី** មានអាសយដ្ឋានផ្ទះលេខ B៧៧E0 ផ្លូវ បេតុងទី២ ភូមិ ទួលគោក សង្កាត់ ទួលសង្កែ ខណ្ឌ ឬស្សីកែវ រាជធានីភ្នំពេញ ដើម្បីដកស្រង់យកបទពិសោធន៍ ក្នុងការប្រកបវិជ្ជាជីវៈមេធាវី ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម លោកប្រធាន មេត្តាពិនិត្យ និង សម្រេចដោយក្តីអនុគ្រោះ។

សូម លោកប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៦

**ហត្ថលេខា និង ឈ្មោះ**

កុក យុឡេង

បានឃើញ និង យល់ព្រម

ធ្វើជាគ្រូកម្មសិក្សា ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៦

**ហត្ថលេខា និង ត្រា**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី. **លឹម វណ្ណា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍**

លេខ: ០៥

ចុះថ្ងៃទី ១៨-០២-២០១៦

# កំណត់ហេតុសច្ចាប្រណិធាន

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែកុម្ភៈ ថ្ងៃទីដប់ប្រាំបី វេលាម៉ោងប្រាំបីព្រឹក បានបើកធ្វើពិធីសច្ចាប្រណិធានជាសាធារណៈនៅសាលាឧទ្ធរណ៍ ដោយមានសមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សា**

- លោក **ខួន អ៊ឹម** ជាប្រធាន
- លោក **សួស សំអាត** ជាចៅក្រុមប្រឹក្សា
- លោក **តូ ពៅស៊ីន** ជាចៅក្រុមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក **ប៉ែន សារ៉ាត** ព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

- លោក **អ៊ុច កែនបូ**

**តំណាងគណៈមេធាវី**

- លោកស្រី **ម៉ុន វិមានចំប៉ា**

**បេក្ខជន-បេក្ខនារី**

-លោក **កុក យូឡេង** (វត្តមាន)

ប្រធានក្រុមប្រឹក្សាប្រកាសសមាសភាព និងប្រកាសបើកពិធីសច្ចាប្រណិធានដោយមានបេក្ខជន ០១រូបលោក **កុក យូឡេង** ។

-តំណាងគណៈមេធាវីលោកស្រី **ម៉ុន វិមានចំប៉ា** បានរាយការណ៍ជូនក្រុមប្រឹក្សាថាបេក្ខជន ០១រូប បានបំពេញបែបបទត្រឹមត្រូវតាមនីតិវិធីហើយ ដោយមានការអនុញ្ញាតពីគណៈមេធាវី និងឯកភាពពីឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីធ្វើសច្ចាប្រណិធាន ចូលប្រកបវិជ្ជាជីវៈជាមេធាវីតាមផ្លូវច្បាប់ តាមមាត្រា៣៤ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី សូមក្រុមប្រឹក្សាដឹកនាំធ្វើការសច្ចាប្រណិធាន។

-**តំណាងមហាអយ្យការសន្និដ្ឋានថា:** ផ្អែកតាមសេចក្តីថ្លែងហេតុ របស់តំណាងគណៈមេធាវី បេក្ខជន រូបនេះ មានគុណសម្បត្តិបានបំពេញនីតិសម្បទាគ្រប់គ្រាន់ អាចប្រកបវិជ្ជាជីវៈ ជាមេធាវីបាន តាមមាត្រា៣៤ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

-ប្រធានក្រុមប្រឹក្សាបានចាត់តាំងឱ្យបេក្ខជនរូបនេះ អានប្រារព្ធវាទដោយផ្ទាល់ ។

-ក្រោយពីការអានប្រារព្ធវាទ ប្រធានក្រុមប្រឹក្សាសាលាឧទ្ធរណ៍ បានបង្គាប់ឲ្យបេក្ខជនលើកដៃស្តាំឡើងលើ រួចថាតាមការអានរបស់ប្រធានក្រុមប្រឹក្សាធ្វើពិធីសច្ចាប្រណិធានថា:

**"ខ្ញុំសូមសច្ចាប្រណិធាន និងអនុវត្តវិជ្ជាជីវៈរបស់ខ្ញុំ ដោយសេចក្តីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយសេចក្តីទៀងត្រង់ ដោយមនុស្សធម៌ ដោយស្មារតីឯករាជ្យ និងដោយគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា"** ។

-ប្រធានក្រុមប្រឹក្សាប្រកាសទទួលស្គាល់ បេក្ខជនលោក **គុក យូឡេង** ជាមេធាវីពេញលក្ខណៈច្បាប់ចាប់ពីថ្ងៃនេះតទៅ ។

-មុនបញ្ចប់ពិធី ប្រធានក្រុមប្រឹក្សា និងតំណាងមហាអយ្យការ បានផ្តល់មតិផ្តាំផ្ញើ ព្រមទាំងជូនពរដល់សមាជិកមេធាវីថ្មី ។

| | |
|---|---|
| ហត្ថលេខា តំណាងគណៈមេធាវី | ហត្ថលេខា បេក្ខជន |
| -លោកស្រី **ម៉ុន វិមានចំប៉ា** | -លោក **គុក យូឡេង** |

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| លោក **អ៊ុច កែនបូ** | លោក **គួ ពៅស៊ុន** , លោក **សួស សំអាត** | លោក **ខួន អ៊ីម** |

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សា**

ខួន អ៊ីម

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"

សាលាឧទ្ធរណ៍ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១

**ក្រឡាបញ្ជី**

អ៊ុច កែនបូ